**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
លេខ៖៣៤៩៤...អបស/ឱអបស

# សារាចរណែនាំ
## ស្តីពី
## ការចែកចាយ និងលក់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩

យោងសេចក្តីណែនាំរបស់គណៈប្រចាំការ នៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គ.ប.ក.) ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២១ ក្រសួងសុខាភិបាល សូមជម្រាបជូនលោក លោកស្រីឱសថការីទទួលបន្ទុកបច្ចេកទេស អគ្គនាយកគ្រឹះស្ថានអាហារណែ នីហារណែឱសថ ម្ចាស់ឱសថស្ថាន ឱសថស្ថានរង និងសាធារណជនទាំងអស់ជ្រាបថា ដើម្បីជំរុញឱ្យមានការចែកចាយ និងលក់ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ឱ្យបានទូលំទូលាយ និងធានាបាននូវគុណភាពដល់អ្នកប្រើប្រាស់ក្នុងការចូលរួមចំណែកទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្រសួងសុខាភិបាលសូមធ្វើការណែនាំដូចតទៅ៖

១. ចំពោះគ្រឹះស្ថានអាហារណែ នីហារណែឱសថ ត្រូវធ្វើការចែកចាយតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដែលមានលេខបញ្ជិកាពីក្រសួងសុខាភិបាល ជូនដល់ឱសថស្ថាន ឱសថស្ថានរង មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល និងគ្លីនិក។

២. ចំពោះឱសថស្ថាន ឱសថស្ថានរង ត្រូវទិញតែតេស្តរហ័សរកអងទីហ្សែនកូវីដ-១៩ ដែលមានលេខបញ្ជិកាពីក្រសួងសុខាភិបាល ហើយលក់ជូនអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល និងប្រជាជនទូទៅដើម្បីប្រើប្រាស់ និងហាមឃាត់ការលក់ និងទិញតេស្តរហ័សនេះតាមប្រព័ន្ធអនឡាញគ្រប់ប្រភេទ។

៣. ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល និងប្រជាពលរដ្ឋ ត្រូវទិញតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដែលមានលេខបញ្ជិកាត្រឹមត្រូវពីឱសថស្ថាន ឱសថស្ថានរងស្របច្បាប់ ហើយត្រូវជៀសវាងការទិញឧបករណ៍តេស្តរហ័សនេះពីតាមប្រព័ន្ធអនឡាញគ្រប់ប្រភេទ ព្រោះឧបករណ៍តេស្តនេះតម្រូវឱ្យមានការទុកដាក់ត្រឹមត្រូវ និងត្រូវមានប្រភពច្បាស់លាស់ បើមិនដូច្នោះទេអាចនឹងប្រឈមជាមួយតេស្តរហ័សដែលមានគុណភាពមិនត្រឹមត្រូវ ឬអាចជាផលិតផលក្លែងបន្លំទៀតផង។

សេចក្តីដូចបានជម្រាបជូនខាងលើ ក្រសួងសុខាភិបាលសង្ឃឹមថា លោក លោកស្រីឱសថការីទទួលបន្ទុកបច្ចេកទេស អគ្គនាយកគ្រឹះស្ថានអាហារណែ នីហារណែឱសថ ម្ចាស់ឱសថស្ថាន ឱសថស្ថានរង និងសាធារណជនទាំងអស់នឹងចូលរួមអនុវត្តតាមសារាចរណែនាំនេះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។

ទទួលបានសារាចរណែនាំនេះ អគ្គនាយកបច្ចេកទេសសុខាភិបាល នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងអភិបាល នៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ ត្រូវផ្សព្វផ្សាយ និងតាមដានការអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ៣រោច ខែអាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១

ម៉ម ប៊ុនហេង

កន្លែងទទួល៖
- លេខាធិការដ្ឋានគណៈប្រចាំការ នៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គ.ប.ក.)
- លេខាធិការដ្ឋានរបស់គណៈប្រតិបត្តិ នៃ គ.អ.ក.
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង
- ឯកសារ កាលប្បវត្តិ